01673114

F66


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens


**អង្គជំនុំជម្រះតុលាការកំពូល**

Supreme Court Chamber

Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier Nº. 002/19-09-2007-ECCC/SC


ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 16-Jun-21, 08:16
CMS/CFO: Sann Rada


នៅចំពោះមុខ៖

**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម ម៉ុង មុនីចរិយា**
**ចៅក្រម Maureen Harding CLARK**
**ចៅក្រម យ៉ា ណារិន**

| | |
|---|---|
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០២១ |
| ភាសាដើម៖ | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

---

# ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២

---

**សហព្រះរាជអាជ្ញា**

ជា លាង
Brenda HOLLIS

**ជនជាប់ចោទ**

ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Megan HIRST

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន
Anta GUISSÉ

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល")

**កត់សម្គាល់ឃើញ**ថា នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រម និងប្រកាសទោសក្នុងសំណុំរឿង ០០២/០២ ដោយផ្ទាល់មាត់នូវសេចក្តីសង្ខេបនៃការយល់ឃើញរបស់ខ្លួន និងផ្នែកសម្រេចសេចក្តីនៃសាលក្រម ហើយបន្ទាប់មក សាលក្រមជាលាយលក្ខណ៍អក្សរត្រូវបានជូនដំណឹងដល់ភាគីជាភាសាខ្មែរ បារាំង និងអង់គ្លេស នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ ("សាលក្រមអង្គជំនុំជម្រះសាលាដំបូង")[1]

**បានទទួល**បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញា[2] និង ខៀវ សំផន[3] និងសារណាតបរបស់ភាគីនីមួយៗ[4]

**រំឭក**ថា នៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១ អង្គជំនុំជម្រះបានចេញដីកាចាត់តាំងចៅក្រមរបាយការណ៍សម្រាប់សវនាការបណ្តឹងសាទុក្ខ ដែលក្នុងនោះ បានចាត់តាំងសហចៅក្រមរបាយការណ៍ពីររូបទទួលបន្ទុកតាមផ្នែកនៃបញ្ហានីមួយៗដែលបានលើកឡើងក្នុងបណ្តឹងសាទុក្ខ[5]

**រំឭក**ថា នៅថ្ងៃដដែលនោះ អង្គជំនុំជម្រះបានចេញការអញ្ជើញដល់ភាគីឱ្យដាក់សេចក្តីសង្កេតលើ

---

[1] ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E1/529.1។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០២ ថ្ងៃទី ១៦ ខែ វិច្ឆកា ឆ្នាំ ២០១៨ ឯកសារលេខ E465។

[2] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿងលេខ ០០២/០២ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F50។

[3] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (សំណុំរឿងលេខ ០០២/០២) ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54។

[4] សារណាតបរបស់ ខៀវ សំផន ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៩ ឯកសារលេខ F50/1។ សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២០ ឯកសារលេខ F54/1។ សារណាតបរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២១ ឯកសារលេខ F54/2។

[5] ដីកាចាត់តាំងសហចៅក្រមរបាយការណ៍ ថ្ងៃទី ២៦ ខែ កម្ភៈ ឆ្នាំ ២០២១ ឯកសារលេខ F59។

កាលវិភាគសវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ដែលក្នុងនោះបានភ្ជាប់ជាមួយនូវកាលវិភាគបណ្តោះអាសន្នដែលភាគីត្រូវបានអញ្ជើញដាក់សេចក្តីសង្កេតរបស់ខ្លួន[6]

**រំឭក**ថា នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២១ ខៀវ សំផន[7] សហព្រះរាជអាជ្ញា[8] និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី(“សហមេធាវីនាំមុខ”)[9] (ជារួមហៅថា “ភាគី”) បានដាក់សេចក្តីសង្កេតរបស់ខ្លួនស្តីពីកាលវិភាគបណ្តោះអាសន្នសម្រាប់សវនាការបណ្តឹងសាទុក្ខ

**រំឭក**ថា នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២១ សហមេធាវីនាំមុខបានដាក់សារណាតបរបស់ខ្លួនទៅនឹងសេចក្តីសង្កេតរបស់ ខៀវ សំផន ស្តីពីកាលវិភាគសវនាការបណ្តឹងសាទុក្ខដែលបានស្នើឡើង[10]

**រំឭក**ថា នៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០២១ អង្គជំនុំជម្រះបានបង្គាប់ថា សវនាការបណ្តឹងសាទុក្ខត្រូវធ្វើឡើងនៅថ្ងៃទី ១៦ ដល់ ២៧ ខែ សីហា ឆ្នាំ ២០២១ និងត្រូវធ្វើឡើងតាមរយៈទម្រង់បែបបទលក្ខណៈចម្រុះដោយសារជំងឺឆ្លងកូវីដ-១៩[11]

**កត់សម្គាល់ឃើញ**ថា ការសង្កេតរបស់ ខៀវ សំផន ដែលបានលើកឡើងថា ការបែងចែកពេលវេលាដែលបានស្នើឡើងនោះ ពុំមានតុល្យភាព និងពុំសមាមាត្រផ្អែកតាមគោលបំណងនៃសវនាការ

---

[6] ការអញ្ជើញភាគីដាក់សេចក្តីសង្កេតលើកាលវិភាគសម្រាប់សវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២១ ឯកសារលេខ F60។

[7] សារណារបស់មេធាវីការពារក្តីពាក់ព័ន្ធទៅនឹងកាលវិភាគសវនាការ (សំណុំរឿង ០០២/០២) ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២១ ឯកសារលេខ F60/1 (“សេចក្តីសង្កេតរបស់ ខៀវ សំផន”)។

[8] សេចក្តីសង្កេតរបរបស់សហព្រះរាជអាជ្ញាលើកាលវិភាគសម្រាប់សវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២១ ឯកសារលេខ F60/2 (“សេចក្តីសង្កេតរបរបស់សហព្រះរាជអាជ្ញា”)។

[9] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកាលវិភាគដែលបានស្នើឡើងសម្រាប់សវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២១ ឯកសារលេខ F60/3 (“សេចក្តីសង្កេតរបស់សហមេធាវីនាំមុខ”)។

[10] សារណាតបរបស់សហមេធាវីនាំមុខទៅនឹងសេចក្តីសង្កេតរបស់ ខៀវ សំផន លើកាលវិភាគសវនាការបណ្តឹងសាទុក្ខដែលបានស្នើឡើង ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២១ ឯកសារលេខ F60/1/1 (“សារណាតបរបស់សហមេធាវីនាំមុខទៅនឹងសេចក្តីសង្កេតរបស់ ខៀវ សំផន”)។

[11] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យារពេលសវនាការបណ្តឹងសាទុក្ខ និងសេចក្តីណែនាំពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទ និងទម្រង់បែបបទសម្រាប់សវនាការបណ្តឹងសាទុក្ខ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០២១ ឯកសារលេខ F65 (ផ្តល់ប្រវត្តិនីតិវិធីបន្ថែមលម្អិតទាក់ទងទៅនឹងកាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ)។

បណ្តឹងសាទុក្ខ ឋានៈខុសៗគ្នារបស់ភាគី និងកម្រិតនៃតួនាទីរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគប្បីដែលត្រូវបានផ្តល់ឱ្យ[12]

**កត់សម្គាល់**បន្ថែមទៀតលើសំណើរបស់ ខៀវ សំផន ស្តីពី (i) វចនាសម្ព័ន្ធនៃសវនាការបណ្តឹងសាទុក្ខ រួមបញ្ចូលទាំងការចំណាយពេលវេលាមួយវគ្គលើទឡ្ហីករណ៍បណ្តឹងសាទុក្ខដែលសំខាន់ពាក់ព័ន្ធទៅនឹងមោឃភាពសាលក្រមអង្គជំនុំជម្រះសាលាដំបូង នៅពេលចាប់ផ្តើមសវនាការបណ្តឹងសាទុក្ខ[13] (ii) ពេលវេលាបែងចែកដល់ភាគី[14] (iii) លំដាប់លំដោយនៃការចូលធ្វើអន្តរាគមន៍របស់ភាគី[15] និង (iv) ឋានៈរបស់សហមេធាវីនាំមុខពាក់ព័ន្ធទៅនឹងវគ្គជាក់លាក់នានា[16]

**កត់សម្គាល់**សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាស្នើសុំការបំភ្លឺលើប្រធានបទតូចៗក្នុងវគ្គមួយចំនួន និងសុំបន្ថែមពេលវេលាលើវគ្គនីមួយៗ[17]

**កត់សម្គាល់**សំណើរបស់សហមេធាវីនាំមុខ (i) សុំបន្ថែមពេលវេលាលើវគ្គជាក់លាក់នានា ព្រមទាំងស្នើសុំការបន្ថែមដែលមានលក្ខណៈសមាមាត្រចំពោះពេលវេលាបន្ថែមដែលផ្តល់ទៅឱ្យ ខៀវ សំផន តាមវគ្គនានាដែលត្រូវបានបែងចែកពេលវេលាឱ្យនោះផងដែរ[18] និង (ii) សុំឱ្យបដិសេធទឡ្ហីករណ៍របស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងបដិសេធសំណើសុំបញ្ចូលមួយវគ្គដាច់ដោយឡែកសម្រាប់ទឡ្ហីករណ៍សំខាន់របស់គាត់[19]

**រំឭកថា** សវនាការបណ្តឹងសាទុក្ខពុំមែនក្នុងគោលបំណងលើកទឡ្ហីករណ៍ដដែល ដែលភាគីបាន

---

[12] សេចក្តីសង្កេតរបស់ ខៀវ សំផន កថាខណ្ឌ ៤ និង ៨ ដល់ ៣១។

[13] សេចក្តីសង្កេតរបស់ ខៀវ សំផន កថាខណ្ឌ ៣២ ដល់ ៣៣។

[14] សេចក្តីសង្កេតរបស់ ខៀវ សំផន កថាខណ្ឌ ៣៤ ដល់ ៣៧ (ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី) កថាខណ្ឌ ៤១ ដល់ ៤៤ (បទឧក្រិដ្ឋ) កថាខណ្ឌ ៤៥ ដល់ ៤៧ (ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល) កថាខណ្ឌ ៥០ ដល់ ៥១ (ការប្រកាសទោស) កថាខណ្ឌ ៥៤ ដល់ ៥៥ (វគ្គបិទសវនាការ)។

[15] សេចក្តីសង្កេតរបស់ ខៀវ សំផន កថាខណ្ឌ ៥២ ដល់ ៥៣។

[16] សេចក្តីសង្កេតរបស់ ខៀវ សំផន កថាខណ្ឌ ៣៨ ដល់ ៤០ (យុត្តាធិការ) កថាខណ្ឌ ៤៨ ដល់ ៤៩ (ការប្រកាសទោស)។

[17] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២ ដល់ ៤ និង ៦ ដល់ ៦។

[18] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខ កថាខណ្ឌ ៣ និង ៥។ សូមមើលផងដែរ សារណាតបរបស់សហមេធាវីនាំមុខទៅនឹងសេចក្តីសង្កេតរបស់ ខៀវ សំផន កថាខណ្ឌ ១១។

[19] សារណាតបរបស់សហមេធាវីនាំមុខទៅនឹងសេចក្តីសង្កេតរបស់ ខៀវ សំផន កថាខណ្ឌ ៣ ដល់ ៨, ១០ និង ១២។

លើកឡើងរួចមកហើយនៅក្នុងសារណាជាលាយលក្ខណ៍អក្សរនោះទេ ប៉ុន្តែជាចម្បងគឺដើម្បីផ្តល់ឱកាសដល់ភាគីធ្វើការឆ្លើយតបទៅនឹងសារណាតបរបស់ភាគីដទៃទៀត និងឆ្លើយសំណួររបស់អង្គជំនុំជម្រះ ប្រសិនបើមាន[20]

**ពិចារណាឃើញថា** តាមការបែងចែកពេលវេលានៅក្នុងកាលវិភាគបណ្តោះអាសន្ន អង្គជំនុំជម្រះបានពិចារណាលើភាពស្មុគស្មាញ និងទឡ្ហីករណ៍ជាច្រើននៃបណ្តឹងសាទុក្ខដែលលើកឡើងដោយភាគីព្រមទាំងតួនាទីជាក់លាក់របស់ភាគី និងពិចារណាឃើញថា ការចូលអន្តរាគមន៍របស់សហមេធាវីនាំមុខគប្បីត្រូវបានកម្រិតត្រឹមបញ្ហា ដែលមានការប៉ះពាល់ដោយផ្ទាល់លើអត្ថប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណី និងពុំគប្បីលើកឡើងវិញនូវទឡ្ហីករណ៍ដែលសហព្រះរាជអាជ្ញាបានលើករួចមកហើយឡើយ[21]

**ពិចារណាឃើញថា** សំណើសុំបន្ថែមពេលវេលាត្រូវបង្ហាញពីអត្ថិភាពនៃ"អត្ថប្រយោជន៍ផ្នែកច្បាប់ជាក់លាក់" ទើបទទួលបានការអនុញ្ញាតការបន្ថែមពេលវេលាដែលស្នើសុំ និងពុំអាចគ្រាន់តែផ្អែកលើសំណើរបស់ភាគីដទៃទៀត ដើម្បីសុំបន្ថែមពេលវេលា និងផលវិបាកពាក់ព័ន្ធឡើយ[22]

**ពិចារណាឃើញថា** ការសង្កេតមួយចំនួនរបស់ភាគី រួមបញ្ចូលការពាក់ព័ន្ធទៅនឹងពេលវេលាបន្ថែម និងការចូលអន្តរាគមន៍ បានធ្វើយុត្តិកម្មដល់វិសោធនកម្មលើកាលវិភាគបណ្តោះអាសន្ន

**ពិចារណាឃើញថា** ទឡ្ហីករណ៍ពាក់ព័ន្ធទៅនឹងឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានលើកហួសវិសាលភាពនៃការអញ្ជើញភាគីឱ្យដាក់សេចក្តីសង្កេតលើកាលវិភាគបណ្តោះអាសន្ន និងកម្មវត្ថុនៃដីកាកំណត់កាលបរិច្ឆេទសវនាការនេះ

**កត់សម្គាល់ឃើញថា** ការកំណត់អត្តសញ្ញាណលើបញ្ហាណាមួយនៅក្នុងកាលវិភាគដែលភ្ជាប់ជាមួយនឹងដីកាកំណត់កាលបរិច្ឆេទ ឬរបាយការណ៍របស់សហចៅក្រមរបាយការណ៍ ពុំអាចត្រូវ

---

[20] *សូមមើល* ដីកាកំណត់កាលវិភាគចុងក្រោយសម្រាប់សវនាការបណ្តឹងសាទុក្ខ និងការជូនដំណឹងដល់ភាគីអំពីបញ្ហាដែលត្រូវលើកឡើង ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/4 ទំព័រ ៣។

[21] សេចក្តីសម្រេចលើសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F10/2 កថាខណ្ឌ ១៧។

[22] ដីកាកំណត់កាលវិភាគចុងក្រោយសម្រាប់សវនាការបណ្តឹងសាទុក្ខ និងការជូនដំណឹងដល់ភាគីអំពីបញ្ហាដែលត្រូវលើកឡើង ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/4 ទំព័រ ៣ ដល់ ៤។

បានបកស្រាយ ថាជាការបញ្ចេញមតិយោបល់របស់អង្គជំនុំជម្រះលើភាពអាចទទួលយកបាននៃទម្រង់ ឬលើអង្គសេចក្ដីនៃបណ្ដឹងសាទុក្ខ

**ពិចារណាឃើញ**ថា សម្រាប់អត្ថប្រយោជន៍ក្នុងការត្រៀមរៀបចំឱ្យបានត្រឹមត្រូវនៃសវនាការបណ្ដឹងសាទុក្ខ ភាគីត្រូវបានតម្រូវឱ្យដាក់ឯកសារមួយចំនួននៅមុនពេលចាប់ផ្ដើមសវនាការ ដូចជា៖ តារាងសំអាងផ្លូវច្បាប់ដែលភាគីមានបំណងផ្អែកទៅលើនៅពេលសវនាការបណ្ដឹងសាទុក្ខ ព្រមទាំងសំអាងផ្លូវច្បាប់ផ្ទាល់

**អាស្រ័យហេតុនេះ៖**

**បង្គាប់**ថា សវនាការបណ្ដឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក. ដោយអនុលោមតាមវិធាន ១០៩ នៃវិធានផ្ទៃក្នុង ត្រូវប្រព្រឹត្តទៅតាមកាលបរិច្ឆេទគ្រោងទុក គឺថ្ងៃ ចន្ទ ទី ១៦ ខែ សីហា ឆ្នាំ ២០២១ នៅម៉ោង ៩ និង ០០ នាទី ព្រឹក និងបន្តចាប់ផ្ដើមតាមម៉ោងដដែលនៅថ្ងៃ អង្គារ ទី ១៧ ខែ សីហា ឆ្នាំ ២០២១ ថ្ងៃ ពុធ ទី ១៨ ខែ សីហា ឆ្នាំ ២០២១ និងព្រហស្បតិ៍ ទី ១៩ ខែ សីហា ឆ្នាំ ២០២១ ព្រមទាំងថ្ងៃ សុក្រ ទី ២០ ខែ សីហា ឆ្នាំ ២០២១ ជាថ្ងៃបម្រុង

**ទទួលយក**ផ្នែកខ្លះនៃសំណើរបស់ភាគីសុំបន្ថែមពេលវេលាលើកសារណានៅពេលសវនាការបណ្ដឹងសាទុក្ខ ដូចដែលបង្ហាញក្នុងតារាងកាលវិភាគភ្ជាប់មកនេះ

**បដិសេធ**ផ្នែកដទៃទៀតនៃសំណើរបស់ភាគីសុំបន្ថែមពេលវេលា

**បញ្ជាក់**ថា ប្រធានបទវគ្គសវនាការមានដូចតទៅ៖

(i) 'ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី' ត្រូវចាប់ផ្ដើមជាមួយនឹងទឡ្ហីករណ៍សំខាន់នៃបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងសុពលភាពនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងរួមបញ្ចូលការពិចារណាជាទូទៅលើគោលការណ៍នីត្យានុកូលភាព

(ii) 'យុត្តាធិការ' រួមបញ្ចូលប្រធានបទតូចៗស្ដីពី*ការបញ្ជូនសំណុំរឿង/វិ*សាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ ភាពគ្រប់គ្រាន់នៃបទចោទក្នុងដីកាដំណោះស្រាយ យុត្តាធិការលើកម្មវត្ថុនៃរឿងក្ដីអង្គហេតុដែលត្រូវបានដកចេញតាមរយៈដីកាបំបែកកិច្ចដំណើរការនីតិវិធី

(iii) 'បទឧក្រិដ្ឋ' រួមបញ្ចូលប្រធានបទតូចៗស្ដីពីច្បាប់(និយមន័យ និងធាតុផ្សំ) ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែល ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធ ព្រមទាំងបញ្ហានីត្យានុកូលភាពពាក់ព័ន្ធ និង

(iv) 'វគ្គបិទសវនាការ' រួមបញ្ចូលបទបង្ហាញសង្ខេបបដិសេធរបស់មេធាវីការពារក្ដីព្រមទាំងឱកាសសម្រាប់ ខៀវ សំផន ថ្លែងទៅកាន់អង្គជំនុំជម្រះដោយផ្ទាល់ ដូចមាននៅក្នុងកាលវិភាគភ្ជាប់នេះ

**បង្គាប់**ថា ភាគីត្រូវដាក់តារាងសំអាងផ្លូវច្បាប់ដែលខ្លួនមានបំណងផ្អែកទៅលើនៅពេលសវនាការបណ្ដឹងសាទុក្ខ ព្រមទាំងសំអាងផ្លូវច្បាប់ផ្ទាល់ ត្រឹមថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០២១

**អញ្ជើញ**ភាគីរៀបរាប់លម្អិតអំពីទឡ្ហីករណ៍របស់ខ្លួន ប្រសិនបើមាន ពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលសវនាការ តាមរយៈពេលវេលាដែលបានបែងចែកតាមវគ្គនីមួយៗក្នុងកាលវិភាគភ្ជាប់នេះ

**រំឭក**ថា អនុលោមតាមវិធាន ១០៩(៦) នៃវិធានផ្ទៃក្នុង ភាគីពុំត្រូវបានអនុញ្ញាតឱ្យលើកបញ្ហានៃអង្គហេតុ ឬអង្គច្បាប់ណាមួយក្នុងអំឡុងពេលនៃសវនាការដែលពុំមាននៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់ខ្លួនឡើយ និង

**ជូនដំណឹង**ថា៖

(i) នៅក្នុងរបាយការណ៍របស់សហចៅក្រមរបាយការណ៍មានភ្ជាប់នូវសំណើសុំការបំភ្លឺ និងសំណួររបស់អង្គជំនុំជម្រះ និងថា ពុំមានការប៉ះពាល់ណាមួយដល់សំណួរដទៃទៀតដែលអង្គជំនុំជម្រះនឹងត្រូវសួរនៅពេលសវនាការ ក្នុងករណីដែលអង្គជំនុំជម្រះអាចមានសំណួរបន្ថែមក្នុងពេលត្រៀមរៀបចំសវនាការបណ្ដឹងសាទុក្ខ ឬនៅពេលសវនាការ ផ្អែកលើសារណារបស់ភាគី

(ii) អង្គជំនុំជម្រះនឹងព្យាយាមធ្វើការបត់បែន ដើម្បីសម្រួលតាមតម្រូវការរបស់ភាគី រួមទាំងការពិចារណាលើសំណើសុំការបែងចែកសាជាថ្មីនូវពេលវេលាដែលនៅសេសសល់សម្រាប់វគ្គនីមួយៗ។

**រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០២១**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**

**ឧបសម្ព័ន្ធ:**

- កាលវិភាគចុងក្រោយសម្រាប់សវនាការបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០២[23]
- របាយការណ៍របស់សហចៅក្រមរបាយការណ៍អនុលោមតាមវិធាន ១០៨(៥) នៃវិធានផ្ទៃក្នុង[24]

[23] កាលវិភាគចុងក្រោយសម្រាប់សវនាការបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០២ ឯកសារលេខ F66.1។

[24] របាយការណ៍របស់សហចៅក្រមរបាយការណ៍អនុលោមតាមវិធាន ១០៨(៥) នៃវិធាផ្ទៃក្នុង ឯកសារលេខ F66.2។